**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៧៤៥ សហវ

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែមេសា ឆ្នាំ ២០០៣

# ប្រកាស
## ស្តីពី
## ការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល
## ប្រចាំ
## វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា,
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា,
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី,
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យសហគ្រាស, សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ,
- បានឃើញអនុក្រឹត្យលេខ ០៧/អនក្រ/បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ,
- បានឃើញអនុក្រឹត្យលេខ ១៧/អនក្រ/បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០០៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា-វ.គ.ស.ក.
- បានឃើញការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

ប្រការ១ : តែងតាំង ឯកឧត្តម **ទី សាយី**, ឋានៈ អនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាស្នងការរាជរដ្ឋាភិបាល ក្នុងអាណត្តិទី១ ប្រចាំវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា **វ.គ.ស.ក.**។

ប្រការ២ : អាណត្តិទី១ ដែលមានរយៈពេលបួន "៤" ឆ្នាំ ត្រូវបានគិតចាប់ពីថ្ងៃទី ០១ ខែឧសភា ឆ្នាំ ២០០៣ ដល់ថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០០៧ ។

ប្រការ៣ : អគ្គលេខាធិការ, នាយកខុទ្ទកាល័យ, ប្រធាននាយកដ្ឋានបុគ្គលិក, ប្រធាននាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ, អង្គភាពពាក់ព័ន្ធ ព្រមទាំងសាមីជន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារៈកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

*កន្លែងទទួល* :-
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- ដូចប្រការ៣
- ឯកសារ/កាលប្បវត្តិ